# គោលការណ៍ ជាមូលដ្ឋានស្តីពីឯករាជ្យភាពរបស់តុលាការ

The Basic Principles on the Independence of the Judiciary

បានអនុម័តដោយមហាសន្និបាតនៃអង្គការសហប្រជាជាតិ នៅក្នុងសេចក្តីសំរេចលេខ ៤០/៣២ ចុះថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ ១៩៨៥ ហើយនឹងសេចក្តីសំរេចលេខ ៤០/១៤៦ ចុះថ្ងៃទី ១៣ ខែធ្នូ ឆ្នាំ១៩៨៥ ។

នេះគឺជាឯកសារសំខាន់មួយ ក្នុងបណ្តាឯកសារនានានៃអង្គការសហប្រជាជាតិ ក្នុងវិស័យសិទ្ធិមនុស្សនៅក្នុងក្របខ័ណ្ឌ នៃការគ្រប់គ្រងរបស់ក្រសួងយុត្តិធម៌។

ដោយហេតុថា ប្រជាពលរដ្ឋគ្រប់ជាន់ថ្នាក់ ក្នុងពិភពលោក ប្តេជ្ញាយ៉ាងមុតមាំថា នឹងបង្កើននូវលក្ខខ័ណ្ឌនានា នៅក្នុងធម្មនុញ្ញ នៃអង្គការសហប្រជាជាតិខាងផ្នែកពង្រឹងនឹងលើកទឹកចិត្តដល់ការគោរពសិទ្ធិមនុស្ស ហើយនឹងការគោរពសេរីភាពជាគ្រឹះ ដោយគ្មានការប្រកាន់ពូជសាសន៍

ដោយហេតុថា ការប្រកាសសិទិមនុស្សជាសកល បានដំកល់ទុកជាពិសេសនូវគោលការណ៍នៃការស្មើភាពគ្នាចំពោះមុខច្បាប់, គោលការណ៍នៃការសន្មត់ថាជនជាប់ចោទទាំងជាអ្នកគ្មានកំហុស (កាលណាតុលាការពុំទាន់កាត់ទោសដាក់ទណ្ឌកម្ម) ហើយ និងគោលការណ៍ដែលប្រកបដោយសិទ្ធិពេញលេញក្នុងការចូលរួមក្នុងសវនាការសាធារណៈដ៏សមរម្យ ដែលរៀបចំឡើងដោយ តុលាការមានសមត្ថកិច្ចឥតលំអៀង និងប្រកបដោយឯករាជ្យភាពតាមលំនាំច្បាប់រដ្ឋ ។

ដោយហេតុថា សន្និសញ្ញាអន្តរជាតិ ស្តីអំពីសិទ្ធិក្នុងវិស័យសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ព្រមទាំង ស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ទាំងពីរនេះបានធានានូវការអនុវត្តន៍ប្រើប្រាស់សិទ្ធិទាំងនោះ ហើយលើសពីនេះទៅទៀត សន្និសញ្ញានៃសិទ្ធិពលរដ្ឋនិង សិទ្ធិនយោបាយបានធានាបន្ថែមនូវសិទ្ធិទទួលការកាត់ទោសពីតុលាការដោយឥតមានការពន្យាពេលដែលពុំសមហេតុសមផល។

ដោយហេតុថារឿយៗតែងតែមានចន្លោះរវាងទស្សនៈដែលជាមូលដ្ឋាននៃគោលការណ៍នានា ហើយនិងស្ថានការណ៍ ពិតៗ


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

ដោយហេតុថាអង្គការនិងអភិបាលនៃផ្នែកអយុត្តិធមិនៅគ្រប់ប្រទេស តែងតែនិយមប្រកាន់យកនូវគោលការណ៍អស់ទាំងនេះ ហើយដោយហេតុថា គេត្រូវតែប្រឹងប្រែងធ្វើយ៉ាងណា ដើម្បីបកស្រាយគោលការណ៍អស់ទាំងនេះ ឲ្យចេញជាភាពពិតៗ ទាំងស្រុង

ដោយហេតុថា បទវិន័យនានាដែលទាក់ទងដល់កិច្ចការនៅក្នុងការិយាល័យតុលាការគួរតែសំដៅយកនូវកត្តាដែលជួយ ញ៉ាំងឲ្យចៅក្រមទាំងឡាយប្រតិបត្តិតាមលំនាំនៃគោលការណ៍ទាំងនេះ

ដោយហេតុថា ចៅក្រមមានអំណាចខ្ពស់បំផុតក្នុងការសំរេចចិត្តដែលអាចប៉ះពាល់ដល់សេរីភាព សិទ្ធិ កាតព្វកិច្ច ហើយ និងទ្រព្យសម្បត្តិរបស់ប្រជាជាតិ

ដោយហេតុថា សន្និបាតទី ៦ នៃអង្គការសហប្រជាជាតិស្តីអំពីការបង្ការឧក្រិដ្ឋកម្ម ហើយនឹងការគ្រប់គ្រងជនដែលប្រព្រឹត្តបទល្មើសតាមសេចក្តីសំរេចរបស់ខ្លួនលេខ ១៦ បានពឹងផ្អែកទៅលើគណៈកម្មាធិការសំរាប់បង្ការនិងត្រួតត្រាឧក្រិដ្ឋកម្ម ដោយរាប់បញ្ចូលទៅក្នុងចំណោមគោលសំខាន់ៗ របស់គេនូវការបរិយាយយ៉ាងល្អិតល្អន់ នៃគោលការណ៍ ណែនាំដែលទាក់ទងដល់ឯករាជ្យភាពរបស់ពួកចៅក្រម ការហ្វឹកហ្វឺន ផ្នែកវិជ្ជាជីវៈ របស់ចៅក្រមព្រមទាំងស្ថានភាពរបស់ពួកចៅក្រម ហើយនឹងពួកសុភាចារបុរស
ព្រោះតែយ៉ាងនេះហើយបានជាគេយល់ថា ជាការប្រពៃណាស់កាលណាគេយកចិត្តទុកដាក់គិតគូរជំបូងបំផុត ទៅលើមុខនាទីរបស់ ចៅក្រមក្នុងវិស័យនៃប្រព័ន្ធយុត្តិធមិ។ រីឯការជ្រើសរើស រើសចៅក្រមការហ្វឹកហ្វឺនចៅក្រម ហើយនិងចរឹតចៅក្រមក៏ជាការ មួយសំខាន់ដែលត្រូវគិតគូរឲ្យបានដិតដល់ដែរ ។

គោលការណ៍ជាមូលដ្ឋានតទៅខាងក្រោមនេះត្រូវបានរៀបចំចងក្រងឡើងក្នុងគោលបំណងដើម្បីជួយរដ្ឋជាសមាជិក នានាក្នុងបេសកកម្មរបស់គេដែលថា ត្រូវតែជំរុញនិងធានាឲ្យមានជាដាច់ខាតនូវឯករាជ្យភាពខាងវិស័យតុលាការ ។

រដ្ឋាភិបាលទាំងឡាយគួរតែយកគោលការណ៍ទាំងនោះទៅប្រើប្រាស់នៅក្នុងវង្វង់ក្របខ័ណ្ឌនៃច្បាប់តុលាការ ហើយនិង ក្របខ័ណ្ឌនៃការអនុវត្ត ព្រមទាំងគួរតែធ្វើការបញ្ជាក់ប្រាប់ដល់គ្រប់ចៅក្រមពួកអ្នកច្បាប់ ហើយនិងសាធារណៈជនជាទូទៅផង ។


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

គោលការណ៍ទាំងនេះរៀបចំចងក្រងឡើង ជាពិសេសសំរាប់ឲ្យចៅក្រមពេញអង្គ (អ្នកយកមុខងារចៅក្រមធ្វើជាវិជ្ជាជីវៈ) អនុវត្តន៍តាម ប៉ុន្តែចៅក្រមតូចតាច ឬចៅក្រមក្រៅក្របខ័ណ្ឌ ក៏អាចអនុវត្តន៍តាមគោលការណ៍នេះ បានយ៉ាងសមរម្យ ដូចគ្នាដែរ ។

## ឯករាជ្យភាពនៃតុលាការ

១- រដ្ឋត្រូវទទួលធានាឲ្យមានឯករាជ្យភាព ខាងវិស័យតុលាការហើយត្រូវដកល់ទុកឯករាជ្យភាពតុលាការនេះនៅក្នុង រដ្ឋធម្មនុញ្ញឬក្នុងច្បាប់ប្រចាំប្រទេស។ គឺជាកាតព្វកិច្ចរបស់ស្ថាប័នគ្រប់ផ្នែក ទាំងផ្នែករដ្ឋាភិបាល និងផ្នែកឯទៀតៗ ក្នុងការគោរព និងប្រតិបត្តិនូវឯករាជ្យភាពនៃតុលាការ ។

២- ក្រសួងតុលាការត្រូវធ្វើការសំរេចរឿងរ៉ាវផ្សេងៗដោយឥតល្អៀង (ឬប្រកាន់បក្សពួក) ។ ការសំរេចត្រូវផ្អែកលើមូលដ្ឋានជាក់ស្តែង ត្រូវស្របតាមលំនាំច្បាប់ មិនត្រូវឲ្យមានការដាក់កំហិត មិនត្រូវឱ្យមានការប្រើឥទ្ធិពលដែលពុំត្រឹមត្រូវ មិន ត្រូវប្រើការអន្ទងឬលួងលោម មិនត្រូវធ្វើការសង្កត់សង្កិន ការគំរាមគំហែង ឬការជ្រៀតជ្រែកដោយចំពោះ ឬដោយមិនចំពោះ អំពីមជ្ឈដ្ឋានណាមួយ ឬ ដោយមូលហេតុណាមួយឡើយ ។

៣- ក្រសួងតុលាការមានអំណាចច្បាប់លើគ្រប់រឿងរ៉ាវទាំងអស់ក្នុងវិស័យតុលាការ ហើយមានអំណាចទាំងស្រុងក្នុង ការសំរេចថាតើរឿងរ៉ាវណាមួយដែលគេបានដាក់ឲ្យតុលាការធ្វើសេចក្តីសំរេចនោះ ស្ថិតនៅក្នុងវង្វង់សមតកិច្ចរបស់ខ្លួនតាមលំនាំ ច្បាប់ឬទេ ។

៤- មិនត្រូវឲ្យមានការជ្រៀតជ្រែកទៅក្នុងកិច្ចការរបស់តុលាការដោយពុំសមស្រប ឬដោយគ្មានដីកាត្រឹមត្រូវឡើយ ។ ការសំរេចឬវិនិច្ឆ័យនានារបស់តុលាការ ពុំត្រូវឲ្យមានការសើរើពិនិត្យឡើងវិញឡើយ។ ប៉ុន្តែគោលការណ៍នេះពុំបានឃាឃាំងមិន អោយមានការសើរើពិនិត្យតាមបែបតុលាការ ឬការបន្ធូរបន្ថយទោស ឬការប្រស្រ័យទាក់ទងពីសំណាក់អាជ្ញាធរមានសមត្ថកិច្ចខាងផ្នែកដាក់ទណ្ឌកម្មដែលតុលាការបានតែងតាំងតាមលំនាំច្បាប់រដ្ឋឡើយ ។

៥- មនុស្សគ្រប់រូបមានសិទ្ធិទទួលការវិនិច្ឆ័យទោសពីតុលាការ ឬសាលាជំនុំជំរះក្តីដោយប្រើនីតិវិធីដែលច្បាប់បានបង្កើត។ សាលាកាត់ក្តី ដែលមិនធ្វើការជំនុំជំរះក្តីតាមនីតិវិធីដែលគេបានចងក្រងយ៉ាងត្រឹមត្រូវតាមលំនាំច្បាប់នេះ ពុំត្រូវបង្កើត អោយមានឡើយ ព្រោះវាអាចប៉ះពាល់ទៅដល់អំណាចច្បាប់របស់តុលាការធម្មតា ឬសាលាជំនុំជំរះក្តីផ្នែកតុលាការ ។


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

៦-គោលការណ៍ស្វយ័ភាពរបស់ក្រសួងតុលាការ បានញ៉ាំងនិងបានតំរូវឲ្យក្រសួងធានាថា ការជំនុំជំរះ ឬការវិនិច្ឆ័យទោស ត្រូវប្រព្រឹត្តទៅដោយសមរម្យត្រឹមត្រូវ ហើយប្រកបដោយការគោរពសិទ្ធិនៃភាគីទាំងអស់ ។

៧- រដ្ឋជាសមាជិកទាំងអស់មានកាតព្វកិច្ច ឧបត្ថម្ភជូន ក្រសួងតុលាការនូវមធ្យោបាយសព្វបែបយ៉ាង ដើម្បីឲ្យដំណើរ ក្រសួងបានសំរេចត្រឹមត្រូវតាមគោលដៅ ។

**សេរីភាពក្នុងការសំដែងមនោសញ្ចេតនា និងការរៀបចំសមាគម**

៨- យោងតាមសេចក្តីប្រកាសសិទ្ធិមនុស្សជាសកល សមាជិកក្រសួងតុលាការ ក៏ដូចជាពលរដ្ឋឯទៀតៗដែរ គឺមាន សេរីភាព ពេញទីក្នុងការបញ្ចេញមនោសញ្ចេតនាក្នុងជំនឿ ក្នុងការបង្កើតសមាគមហើយនឹងការរួមប្រជុំគ្នា។ ប៉ុន្តែក្នុងការប្រើប្រាស់សិទ្ធិ សេរីភាពរបស់ខ្លួន ចៅក្រមទាំងពួងត្រូវតែប្រកាន់យកនូវឥរិយាបថ ដែលប្រកបដោយសេចក្តីថ្លៃថ្នូចំពោះមុខក្រសួងរបស់ខ្លួន ហើយត្រូវឈរលើជំហរឥតល្អៀងហើយនឹងឯករាជ្យភាពក្នុងវិស័យតុលាការ ។

៩- ចៅក្រមទាំងឡាយ ត្រូវមានសេរីភាពពេញទីក្នុងការបង្កើត និងចូលរួមក្នុងសមាគមជាមួយចៅក្រមឯទៀត ឬចូលរួមជាមួយអង្គការឯទៀតៗ ដើម្បីដំណាងអត្ថប្រយោជន៍ខ្លួនគេ ឬដើម្បីជំរុញការហ្វឹកហ្វឺនមុខវិជ្ជាជីវៈរបស់គេ ព្រមទាំងដើម្បី ការពារឯករាជ្យភាពរបស់គេក្នុងវិស័យតុលាការ ។

**គុណសម្បត្តិសំរាប់កាន់តំណែង ការជ្រើសរើស និងការហ្វឹកហ្វឺន**

១០- បុគ្គលិកសំរាប់ក្រសួងតុលាការ ត្រូវតែជាបុគ្គលដែលមានសេចក្តីសុចរិតទៀតត្រង់ មានការប៉ិនប្រសប់ ហើយត្រូវប្រកបដោយការហ្វឹកហ្វឺនយ៉ាងគ្រប់គ្រាន់ និងត្រឹមត្រូវ ឬប្រកបដោយគុណសម្បត្តិខ្ពង់ខ្ពស់ខាងច្បាប់តុលាការ។ ការជ្រើសរើស បុគ្គលិកក្រសួងតុលាការ ទោះបីតាមវិធីណាក៏ដោយ ក៏ត្រូវតែប្រុងប្រយ័ត្ន ជានិច្ចកុំឲ្យមានការចាត់តាំងបុគ្គលិក ដោយបណ្តាលមកពីមូលហេតុពុំសមរម្យ។ ក្នុងការជ្រើសរើសចៅក្រម ពុំត្រូវឲ្យមានការរើសអើង (ឬប្រកាន់) ដោយសំអាងទៅលើពូជ កំណើត ពណ៌សម្បុរ ភេទ សាសនា គោលជំហរនយោបាយ សញ្ជាតិ ឬកំណើតសង្គម ទ្រព្យសម្បត្តិ កំណើតឬស្ថានភាពអ្វីឡើយ ក្រៅតែអំពីសេចក្តីតំរូវមួយដែលថាបេក្ខជនសំរាប់តុលាការត្រូវតែមាន សញ្ជាតិជាពលរដ្ឋនៃប្រទេសដែលខ្លួនរស់នៅ ហើយការពិនិត្យពិច័យទៀត ក៏មិនត្រូវអោយមានការប្រកាន់បក្សពួកដែរ ។


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

## ល័ក្ខខ័ណ្ឌការងារ និង ការកាន់មុខតំណែង

១១- អាណត្តិនៃការងាររបស់ចៅក្រម ស្វ័យភាពការឧបតម្ភសំរាប់គ្រាអាសន្ន ការឲ្យប្រាក់រង្វាន់ ល័ក្ខខ័ណ្ឌការងារ ប្រាក់រីត្រែតហើយនឹងអាយុវ័យសំរាប់រីត្រែត (ចូលនិវត្តន៍) ត្រូវទទួលការធានារ៉ាប់រងយ៉ាងគ្រប់គ្រាន់អំពីច្បាប់រដ្ឋ ។

១២- ចៅក្រមទាំងពួងទោះបីគេត្រូវតែងតាំង ឬបោះឆ្នោតជ្រើសរើសត្រូវតែទទួលនូវមុខតំណែងដែលប្រកបដោយ ការធានារ៉ាប់រងជានិច្ចកាលរហូតដល់អាយុចូលនិវត្តន៍ តាមកាលកំណត់របស់រដ្ឋ ឬរហូតដល់ថ្ងៃចប់អាណត្តិនៃមុខងារ ។

១៣- ប្រសិនបើមានការតំលើងឋានន្តរសក្តិ ឲ្យពួកចៅក្រមគេត្រូវសំអាងទៅលើកត្តាដែលជាគោលដៅនានាដូចមានជាពិសេសការប៉ិនប្រសព្វ ភាពសុចរឹតទៀងត្រង់ ហើយនិងការពិសោធន៍ ។

១៤- ចំពោះការចែកមុខងារឲ្យចៅក្រមដែលនៅធ្វើការនៅក្នុងបរិវេណតុលាការគឺជាកិច្ចការផ្ទៃក្នុងរបស់ក្រុមអភិបាលនៃតុលាការនោះ ។

## អាថ៌កំបាំងក្នុងមុខរបរ និង អភ័យឯកសិទ្ធិ

១៥- ក្នុងការពិគ្រោះពិភាក្សា ឬក្នុងការគិតគូរនានាក្នុងការងារតុលាការ ក្រសួងតុលាការត្រូវតែប្រកាន់យកនូវវត្តិយាបថ រក្សាអាថិកំបាំងក្នុងមុខរបរខ្លួនជាដាច់ខាត។ រីឯពត៌មានសំងាត់ (អាថិកំបាំង) ដែលខ្លួនបានទទួលក្នុងពេលកំពុងបំពេញ ភារកិច្ចដទៃអំពីទំរង់ការសាធារណៈក៏ត្រូវរក្សាទុកអាថិកំបាំងដែរ។ ម៉្យាងវិញទៀត មិនត្រូវបង្ខំអោយតុលាការបកស្រាយអំពី រឿងនានា ដែលជាអាថិកំបាំងឡើយ ។

១៦- បើពុំបានធ្វើឲ្យប៉ះពាល់ ឬបំពាបំពានទៅលើនីតិវិធីខាងពង្រឹងបទវិន័យណាមួយ ឬទៅលើសិទ្ធិអំពាវនាវ (ដើម្បីសុំអោយតុលាការធ្វើការកាត់សេចក្តីសារជាថ្មី) ឬពុំបានធ្វើឲ្យខូចខាតលទ្ធភាពនៃការសងជំងឺចិត្តអំពីសំណាក់ រដ្ឋាភិបាលទេនោះ ពោលគឺបើគ្រាន់តែធ្វើឲ្យមានការខាតបង់ប្រាក់កាសដោយសារអំពើពុំគប្បី ឬបើគ្រាន់តែប្រព្រឹត្តឆ្គាំឆ្គង ក្នុងមុខការរបស់ខ្លួនទេនោះ ច្បាប់រដ្ឋចែងថាពួកចៅក្រមទាំងអស់មានអភ័យឯកសិទ្ធិពេញទី។ បើនិយាយឲ្យខ្លីគឺគ្មាននរណាអាចប្តឹងចោទចៅក្រមដោយ សារកំហុសបន្តិចបន្តួចនេះបានទេ ។

## បទវិន័យ, ការបញ្ឈប់ជាបណ្តោះអាសន្ន និងការដកចេញពីមុខតំណែង


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល

១៧- បើមានការចោទប្រកាន់ ឬពាក្យប្តឹងតវ៉ាទៅលើរូបចៅក្រមណាមួយ ក្នុងឋានៈជាអ្នកប្រកបអាជីវកម្មខាងវិស័យ កិច្ចការតុលាការ គេត្រូវយករឿងនេះទៅដោះស្រាយឲ្យបានរួសរាន់ និងសមរម្យតាមនីតិវិធីដ៏ត្រឹមត្រូវ។ ចៅក្រមរូបនេះត្រូវ មានសិទ្ធិសាកសួរហេតុផលនិងឆ្លើយដោះសារ។ ការពិនិត្យពិចារណាទៅលើរឿងរ៉ាវក្នុងដំណាក់កាលជាដំបូងនេះត្រូវរក្សាទុក ជាអាថ៌កំបាំងជានិច្ចប្រសិនបើគ្មានការស្នើសុំពីសំណាក់ចៅក្រមនេះទេ ។

១៨- ចៅក្រមណាដែលត្រូវគេរកឃើញថា ខ្លួនខ្វះសមត្ថភាព ឬប្រកបដោយអត្តចរិកដែលពុំអាចអោយខ្លួនបំពេញ កាតព្វកិច្ចក្នុងនាមជាចៅក្រម បាននឹងត្រូវបញ្ឈប់ជាបណ្តោះអាសន្ន ឬត្រូវដកហូតចេញពីមុខតំណែង ។

១៩- ទំរង់ការជានាសំរាប់ពង្រឹង បទវិន័យគឺការដាក់ទណ្ឌកម្ម សំរាប់បញ្ឈប់ពីការងារបណ្តោះអាសន្ន ឬសំរាប់ដកហូត ចៅក្រមចេញពីមុខតំណែង ត្រូវបានសំរេចដោយអនុលោមតាមកំរិតនៃគោលច្បាប់ខាងវិស័យកិរិយាមារយាទចៅក្រមដែលគេ បានតាក់តែងទុក ។

២០- ការសំរេចនានាស្តីអំពីការដាក់ទណ្ឌកម្ម ការបញ្ឈប់ជាបណ្តោះអាសន្ន ឬការដកហូតពីតំណែងត្រូវអនុញ្ញាតឲ្យ មានការសើរើពិនិត្យជាលក្ខណៈឯករាជ្យភាព ប៉ុន្តែចំពោះករណីដែលមានការសំរេចពីតុលាការជាន់ខ្ពស់បំផុត ហើយនឹងសេចក្តី សំរេចពីសំណាក់ក្រុមនីតិវិធីបញ្ញត្តិដែលធ្វើការចោទប្រកាន់នៅចំពោះមុខតុលាការ ឬពីសំណាក់ទំរង់ការណាដែលស្រដៀងនឹងករណីខាងដើមនេះ គោលការណ៍នៃការសើរើពិនិត្យជា លក្ខណៈឯករាជ្យភាពប្រហែលជានឹងពុំត្រូវបានអនុញ្ញាតឡើយ ។

ប្រភព៖

បកប្រែ៖

វាយឡើងវិញ៖ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលសំរាប់រៀបចំកាត់សេចក្តីមេដឹកនាំខ្មែរក្រហម


រក្សាសិទ្ធិ © ២០០៤ ដោយលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាល